## ការណែនាំអំពីការរកលំនៅរបស់ជនជាតិបរទេស

## តើយើងគួរប្រុងប្រយ័ត្នអ្វីខ្លះពេលយើងជួលផ្ទះបានហើយ?

សៀវភៅណែនាំនេះសរសេរបង្ហាញប្រាប់យើងអោយដឹងពី វិធីគួរប្រុងប្រយ័ត្នមួយចំនួននៅពេលដែលយើង ជួលផ្ទះ ដូចជា៖

- អំពីអ្វីដែលត្រូវធ្វើបន្ទាប់ពីជួលផ្ទះបាន
- អំពីច្បាប់និងឥរិយាបទនៃការរស់នៅ
- អំពីអ្វីដែលត្រូវធ្វើនៅពេលរើចេញពីផ្ទះដែលយើងបានជួល

## អំពីមជ្ឈមណ្ឌលជួយគាំទ្រទីលំនៅរបស់ជនបរទេស នៅ ខេត្តកាណាហ្កាវ៉ា

មជ្ឈមណ្ឌលជួយគាំទ្រទីលំនៅរបស់ជនបរទេស ដោយមិនគិតកំរៃរបស់ ខេត្តកាណាហ្កាវ៉ា បង្កើតឡើង ដើម្បីជួយស្វែងរកផ្ទះដល់ជនជាតិបរទេសដែលមិនចេះភាសាជប៉ុន ព្រមទាំងជួយផ្តល់នូវដំបូន្មានផ្សេងៗ ដើម្បីដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងលំនៅស្ថានស្នាក់នៅ។

យ៉ូកូហាម៉ា YMCA

ស្ថានីយសេគីអ៊ូជី រថភ្លើងក្រោមដី ក្រុងយ៉ូកូហាម៉ា

រថភ្លើង JR នៃ ស្ថានីយសេគីអ៊ូជី




ស្ថានីរថភ្លើងស្គាត យ៉ូកូហាម៉ា

សាលាក្រុងយ៉ូកូហាម៉ា

អាស័យដ្ឋាន : យ៉ូកូហាម៉ា YMCA ជាន់ទី២ ១-៧ សង្កាត់តូគីវ៉ា ក្រុងយ៉ូកូហាម៉ា

ស្ថានីរថភ្លើងស្គាត យ៉ូកូហាម៉ា

ជិះតាមរថភ្លើង JR រហូតដល់ ស្ថានីសេគីអ៊ូជី រថភ្លើងក្រោមដីក្រុងយ៉ូកូហាម៉ា រួចដើរ ៥នាទី

ជិះតាមខ្សែរថភ្លើងមីណាតុមីរ៉ៃ រហូតដល់ ស្ថានីនីពប៉ុនអូដូរី រួចដើរ ៥នាទី

លេខទូរស័ព្ទ : 045-228-1752 លេខទូរសារ: 045-228-1768

អ៊ីម៉ែល : sumai.sc@sumasen.com

វ៉ិបសាយ : http://www.sumasen.com/

ចងក្រងឡើងក្នុងខែកុម្ភៈ ឆ្នាំ២០១៣

# I អ្វីដែលចាំបាច់ត្រូវធ្វើ និង ចងចាំនៅពេលដែលជួលផ្ទះបាន

## 1 ត្រូវពិនិត្យក្នុងផ្ទះដូចជា

1) ពេលធ្វើកិច្ចសន្យាជួលផ្ទះរួចរាល់ គេនឹងប្រគល់សោរផ្ទះអោយអ្នក ហើយអ្នកត្រូវ ប្រគល់សោអោយគេវិញ ពេកដែលអ្នករើចេញ ដូច្នេះអ្នកត្រូវរក្សាទុកសោរនោះអោយបានល្អ។

2) ចាំបាច់ត្រូវពិនិត្យ

   A ពិនិត្យទ្វារ និង បង្អួច អោយបានត្រឹមត្រូវថាមានខូច រឺ បែកបាក់រឺទេ

   B ពិនិត្យសោរអោយបានម៉ត់ចត់ ថាអាចប្រើបានរឺទេ

   C ពិនិត្យមើលកំរាលនិងជញ្ជាំង ថាមានស្នាមដាច់ រឺ ប្រឡាក់ទេ

   * សូមពិនិត្យអោយបានច្បាស់លាស់ជាមួយម្ចាស់ផ្ទះ រឺ ក្រុមហ៊ុនអចលនទ្រព្យនៅពេលមានបញ្ហាអ្វីមួយ។

## 2 ការធ្វើបែបបទតបណ្តាញភ្លើងអគ្គិសនី

1) មុនពេលប្រើភ្លើងអគ្គិសនី សូមទាក់ទងទៅក្រុមហ៊ុនអគ្គិសនីតូក្យូជាមុនសិន។ សូមសួរបញ្ជាក់ទៅក្រុមហ៊ុន អចលនទ្រព្យ ថាតើគេបានទាក់ទងទៅក្រុមហ៊ុនអគ្គិសនីតូក្យូ អោយអ្នកហើយរឺនៅ។

2) ក្នុងករណីអ្នកត្រូវទាក់ទងទៅក្រុមហ៊ុនដោយខ្លួនឯង សូមស៊ើបសួរនិងទាក់ទងសាខារបស់ក្រុមហ៊ុនដែល នៅជិតកន្លែងដែលអ្នករស់នៅ។

3) ពេលចូលស្នាក់នៅ សូមបើកកុងតាក់ចរន្តភ្លើង(ប៉ាណ៊ែតភ្លើង) រួចពិនិត្យថា អំពូលភ្លើង ម៉ាស៊ីនត្រជាក់ និង ឧបករណ៍អគ្គិសនីផ្សេងៗទៀតដំណើរការដែររឺទេ។

4) សូមពិនិត្យតង់ស្យុងភ្លើង(អំពែ)អោយបានច្បាស់លាស់។

5) នៅពេលណាមួយដែលភ្លើងអគ្គិសនីមិនអាចប្រើប្រាស់បាន សូមពិនិត្យកុងតាក់ចរន្តភ្លើង(ប៉ាណ៊ែតភ្លើង)។

6) សូមពិនិត្យថាតើគេមានតខ្សែបណ្តាញទូរស័ព្ទ និង អ៊ីនធឺណេតអោយអ្នកហើយរឺនៅ។

## 3 ការធ្វើបែបបទតបណ្តាញហ្គាស

1) ដើម្បីអាចប្រើហ្គាសបាន ក្រុមហ៊ុនហ្គាសត្រូវរៀបចំប្រព័ន្ធហ្គាសក្នុងផ្ទះជាមុនសិន ដូច្នេះអ្នកត្រូវទាក់ទងទៅ ក្រុមហ៊ុនហ្គាសដើម្បីកំណត់ថ្ងៃដែលត្រូវរៀបចំប្រព័ន្ធហ្គាសនោះ។

2) ត្រូវមាននរណាម្នាក់ក្នុងគ្រួសារអ្នកនៅចាំផ្ទះ នៅថ្ងៃដែលក្រុមហ៊ុនចូលទៅរៀបចំប្រព័ន្ធហ្គាស។

3) នៅពេលនោះអ្នកត្រូវសុំអោយ ក្រុមហ៊ុនពន្យល់ពីរបៀបប្រើប្រាស់ហ្គាសអោយបានច្បាស់លាស់។

## 4 ការធ្វើបែបបទតបណ្តាញទឹកប្រើប្រាស់

1) មុនពេលប្រើប្រាស់ទឹក សូមទាក់ទងទៅរដ្ឋាករទឹក ជាមុនសិន។ សូមសួរបញ្ជាក់ទៅក្រុមហ៊ុនអចលនទ្រព្យ ថាតើគេបានទាក់ទងទៅរដ្ឋាករទឹក អោយអ្នកហើយរឺនៅ។

2) ក្នុងករណីអ្នកត្រូវទាក់ទងទៅរដ្ឋាករទឹកដោយខ្លួនឯង សូមស៊ើបសួរនិងទាក់ទងរដ្ឋាករទឹកដែលនៅជិត កន្លែងដែលអ្នករស់នៅ។

3) ពេលចូលស្នាក់នៅ សូមពិនិត្យកក្បាលរ៉ូប៊ីណេទឹក អាងត្រាំទឹក បង្គន់អនាម័យ ជាដើម ថាតើមានជ្រាបទឹក រឺខូចដែលមិនអាចប្រើប្រាស់បានដែររឺទេ។

## 5 ការស្នើសុំតភ្ជាប់បណ្តាញទូរស័ព្ទក្នុងផ្ទះ (ក្នុងករណីចាំបាច់)

1) ក្នុងករណីអ្នកចង់តភ្ជាប់បណ្តាញទូរស័ព្ទក្នុងផ្ទះ សូមទាក់ទងទៅក្រុមហ៊ុនទូរស័ព្ទដែលនៅជិតកន្លែងដែល អ្នករស់នៅ។

# II អំពីច្បាប់និងឥរិយាបទនៃការរស់នៅ

## 1 ពេលស្នាក់នៅ

1) ពេលដើរជួបអ្នកស្នាក់នៅជិតខាង នៅតាមផ្លូវចូលផ្ទះ រឺ ជណ្តើរយន្ត សូមសួរស្តីទៅកាន់គេ ដោយនិយាយ ថា "កុននីជីវ៉ា" ("Kon-nichiwa") ជាដើម។

## 2 បែបបទ និង របៀបនៃការចោលសំរាម

1) នៅប្រទេសជប៉ុន គេចោលសំរាមទៅតាមប្រភេទរបស់វា និងមានលក្ខណៈខុសគ្នាបន្តិចបន្តួចទៅតាមតំបន់ និងក្រុង។ ដោយសារតែរបៀបទាំងនោះខុសពីប្រទេសរបស់អ្នក ដូច្នេះហើយអ្នកត្រូវ សួរសាលាឃុំ រឺសង្កាត់ អំពី របៀបបែងចែកសំរាម កន្លែងដាក់ និងថ្ងៃដែលត្រូវចោលសំរាមអោយបានច្បាស់លាស់។

2) ម្យ៉ាងវិញទៀតការចោលសំរាមក៏អាចខុសគ្នាទៅតាមសហគមន៍ រឺអគារដែរ ដូច្នេះជាការប្រសើរ អ្នកត្រូវ សាកសួរ ក្រុមហ៊ុនអចលនទ្រព្យ រឺអ្នកគ្រប់គ្រងនៅក្នុងអគារនោះ។

3) កន្លែងដាក់ រឺចោលសំរាមត្រូវបានគេកំណត់ត្រឹមត្រូវ។

4) នៅពេលដែលអ្នកបែងចែកសំរាមមិនបានល្អ រឺ ដាក់ខុសកន្លែង រឺ ដាក់ចោលខុសថ្ងៃ នោះក្រុមហ៊ុនប្រមូល សំរាម នឹងមិនប្រមូលសំរាមទាំងនោះរបស់អ្នកទេ ទាំងនោះបណ្តាលអោយប៉ះពាល់ដល់អ្នកដ៏ទៃដែលនៅជុំ វិញខ្លួនអ្នកទៀតផង។

【ឧទាហរណ៍ពីរបៀបចោលសំរាម】 (ការចោលសំរាមខុសគ្នាទៅតាមតំបន់)

A សំរាមដូចជា ផ្លាស្ទីក ដបជ័រ ដប កំប៉ុង ជាដើម ត្រូវចែកជាប្រភេទ ហើយដាក់ក្នុងថង់ដែលគេបានកំន ត់រួចទើបយកទៅចោល។ យើងទាំងអស់គ្នារួមគ្នាកាត់បន្ថយសំរាមស្រស់។

B ពេលអ្នកច្រលំ រឺភ្លេចម៉ោង រឺថ្ងៃចោលសំរាម អ្នកត្រូវរក្សាទុកសំរាមនោះនៅផ្ទះរបស់អ្នកសិន រងចាំ ចោលនៅ ថ្ងៃដែលត្រូវចោលបន្ទាប់។

C ដើម្បីចោល សំរាមធំៗធ្ងន់ៗដូចជា គ្រឿងដែកធំៗ គ្រឿងផ្លាស្ទីកធំៗ គ្រឿងឈើធំៗ ផ្ទាំងកញ្ចក់ ជា ដើម អ្នកត្រូវស្នើសុំទៅសាលាក្រុង រឺក្រុមហ៊ុនសំអាត ដើម្បីមកដឹកប្រមូលវា ហើយអ្នកត្រូវចំណាយ ប្រាក់ទៅលើការចោលសំរាមប្រភេទទាំងនេះ។

## 3 អំពីបញ្ហាសំលេងរំខាន

1) សូមអ្នកប្រយ័ត្នទៅលើការបើកចំរៀង រឺភ្លេងលឺៗ ដូចជានៅពេលអ្នកធ្វើពិធីជប់លៀង ជាដើម។ជាពិសេស សូមរក្សាភាពស្ងៀមស្ងាត់នៅពេលយប់។

2) សូមពិភាក្សាជាមួយក្រុមហ៊ុនអចលនទ្រព្យ នៅពេលដែលអ្នកជិតខាងមានសំលេងឡូឡារំខានដល់អ្នក។

## 4 អំពីអ្វីដែលគេហាមឃាត់ និង អ្វីដែលត្រូវគោរព

1) នៅពេលដែលអ្នកចង់ចិញ្ចឹមសត្វនៅក្នុងផ្ទះ អ្នកត្រូវសួរបញ្ជាក់ទៅក្រុមហ៊ុនអចលនទ្រព្យ រឺម្ចាស់ផ្ទះជាមុន សិន ថាតើអ្នកអាចចិញ្ចឹមបានដែររឺទេ។ វាជាការបំពានកិច្ចសន្យា នៅពេលដែលអ្នកលួចចញ្ចឹមសត្វដោយគ្មាន ការអនុញ្ញាតនោះ។

2) អ្នកមិនគួរដំដែកគោល រឺចោះប្រហោងផ្សេងៗ នៅលើសសរ និងជញ្ជាំងផ្ទះទេ។

3) កន្លែងមួយចំនួនដូចជា ផ្លូវដើរចូលផ្ទះ កាំជណ្តើរ ជាកន្លែងសំរាប់ប្រើរួមគ្នាជាមួយអ្នកជិតខាង និងជាផ្លូវសំ រាប់រត់គេចខ្លួននៅពេលមានរញ្ជួយដី រឺអគ្គីភ័យ ដូច្នេះអ្នកមិនត្រូវទុកដាក់សំរាម ជើងផ្កា កង់ ជាដើមនៅទី កន្លែងទាំងនោះទេ។ អ្នកអាចត្រូវ ផ្តែកអង្គភាពអគ្គីភ័យប្រមាន រឺស្តីបន្ទោសអោយ ក្នុងករណីនោះ។

4) អ្នកក៏មិនត្រូវដាក់របស់របរ នៅរានហាល(ប៉េរ៉ង់ដា)ទេ ព្រោះ ទីនោះក៏ជាផ្លូវសំរាប់រត់គេចខ្លួនពេលមាន អាសន្នផងដែរ។

5) អ្នកមិនត្រូវអនុញ្ញាតអោយអ្នកណាម្នាក់ ក្រៅពីសមាជិកដែលអ្នកបានប្រាប់ទៅក្រុមហ៊ុនអចលនទ្រព្យ ស្នា ក់នៅក្នុងផ្ទះនោះទេ។

6) អ្នកត្រូវបង់ថ្លៃឈ្នួលផ្ទះអោយបានទៀងទាត់ និងទាន់ពេលវេលា។

* យើងត្រូវនាំគ្នារស់នៅដោយ គោរពច្បាប់ និង ប្រកបដោយសីលធម៌ល្អទាំងអស់គ្នា។យើងត្រូវសាកសួរទៅ អ្នកជិតខាង នូវអ្វីដែលយើងមិនទាន់ដឹង និងមិនទាន់យល់ច្បាស់។

# III អ្វីដែលចាំបាច់ត្រូវធ្វើមុនពេលអ្នករើចេញពីផ្ទះដែលបានជួល

## 1 ត្រូវទំនាក់ទំនងអំពីការរើចេញ

1) ករណីអ្នកចង់រើចេញអ្នកត្រូវទាក់ទងប្រាប់ដំណឹង ទៅក្រុមហ៊ុនអចលនទ្រព្យ រឺម្ចាស់ផ្ទះអោយបាន១ រឺ ២ខែ មុនពេលកិច្ចសន្យាផុតកំណត់។

## 2 ត្រូវទំនាក់ទំនងទៅកាន់ក្រុមហ៊ុនអគ្គិសនីតូក្យូ ក្រុមហ៊ុនហ្គាស និង រដ្ឋាករទឹក

1) អ្នកត្រូវទំនាក់ទំនងទៅកាន់ក្រុមហ៊ុនអគ្គិសនីតូក្យូ ក្រុមហ៊ុនហ្គាស និង រដ្ឋាករទឹក អោយបាន ១សប្តាហ៍មុន ពេលអ្នករើចេញ។

2) នៅថ្ងៃដែលអ្នករើចេញនោះ ក្រុមហ៊ុនអគ្គិសនីតូក្យូ ក្រុមហ៊ុនហ្គាស និង រដ្ឋាករទឹកនឹងមកផ្ទះអ្នកដើម្បីធ្វើ បែបបទផ្តាច់ការប្រើប្រាស់ ដូច្នេះអ្នកត្រូវទាក់ទងសួរពួកគេអោយបានច្បាស់ជាមុនអំពីរបៀបនៃការបង់ប្រាក់។

## 3 ត្រូវទំនាក់ទំនងទៅកាន់ក្រុមហ៊ុនទូរស័ព្ទ អ៊ីនធឺណេត និង ប៉ុស្តិ៍ប្រៃសនី

1) ត្រូវទំនាក់ទំនងទៅកាន់ក្រុមហ៊ុនទូរស័ព្ទលើតុដែលអ្នកបានធ្វើកិច្ចសន្យាជាមួយ។

2) ត្រូវទំនាក់ទំនងទៅកាន់ក្រុមហ៊ុនទូរស័ព្ទដៃដែលអ្នកបានធ្វើកិច្ចសន្យាជាមួយ។

3) ត្រូវទំនាក់ទំនងទៅកាន់ក្រុមហ៊ុនអ៊ីនធឺណេតដែលអ្នកបានធ្វើកិច្ចសន្យាជាមួយ។

4) ត្រូវទំនាក់ទំនងទៅកាន់ប៉ុស្តិ៍ប្រៃសនីដើម្បីប្រាប់ពីអាស័យដ្ឋានថ្មីរបស់អ្នក។

## 4 ការចោលសំរាមប្រភេទធំៗ

1) នៅពេលមានសំរាមធំៗច្រើនដូចជា គ្រឿងសង្ហារឹមចាស់ជាដើមនោះ អ្នកត្រូវទាក់ទងទៅកាន់សាលាក្រុងរឺ ក្រុមហ៊ុនប្រមូលសំរាម ដើម្បីទទួលការណែនាំអំពីវិធីនៃការចោលសំរាមទាំងនោះ។

2) ក្នុងករណីដែលថ្ងៃចោលសំរាមធំៗប្រភេទនេះនៅក្រោយថ្ងៃដែលអ្នករើចេញផុត អ្នកត្រូវពិភាក្សាជាមួយ ម្ចាស់ផ្ទះ រឺអ្នកគ្រប់គ្រងអគារដែលអ្នកបានស្នាក់នៅនោះ។

## 5 ការដឹកជញ្ជូនឥវ៉ាន់

1) អ្នកត្រូវរើជញ្ជូនឥវ៉ាន់នៅពេលថ្ងៃ ព្រោះការជញ្ជូននៅពេលយប់រាំខានដល់អ្នកជិតខាង។

2) អ្នកត្រូវប្រមូលសំភារះអោយអស់ ដោយមិនត្រូវបន្សល់សំរាមរឺរបស់ផ្សេងៗ នៅក្នុងផ្ទះទេ ហើយអ្នកត្រូវ សំអាតផ្ទះអោយបានស្អាតផង មុននឹងចាកចេញ។

## 6 មុនពេលចាកចេញពីផ្ទះ

1) ត្រូវប្រគល់សោរអោយក្រុមហ៊ុនអចលនទ្រព្យវិញ។

2) ត្រូវពិនិត្យមើលស្ថានភាព រឺលក្ខណះផ្ទះជាមួយម្ចាស់ផ្ទះ រឺក្រុមហ៊ុនអចលនទ្រព្យថាតើមានខូចខាតអ្វី រឺត្រូវ ជួសជុលអ្វីសងគេវិញរឺទេ។

* ជាទូទៅ មុនពេលចាកចេញអ្នកត្រូវ ជួសជុលធ្វើអ្វីដែលបាក់បែកខូចខាត អោយម្ចាស់ផ្ទះគេវិញ។

## 7 **ការទូទាត់ប្រាក់កក់**

1) ជាទូទៅត្រូវបានសងត្រលប់អោយអ្នកវិញ ប៉ុន្តែប្រាក់កក់អាចនឹងត្រូវបានម្ចាស់ផ្ទះដកទុកមួយចំនួន ប្រសិនបើអ្នកបានធ្វើអោយខូចខាត បែកបាក់ផ្នែកណាមួយ រឺបាត់បង់សំភារៈណាមួយក្នុងផ្ទះនោះ។
2) ម្យ៉ាងវិញទៀត អ្នកអាចនឹងត្រូវបង់លុយបន្ថែមទៀត ក្នុងករណីដែលលុយកក់ទាំងនោះមិនអាច រ៉ាប់រងសង គ្រប់គ្រាន់នៅទំហំខូចខាតនោះ។

---

សៀវភៅណែនាំនេះបកប្រែសំរួលជាភាសាខ្មែរ ចេញពីសៀវភៅណែនាំច្បាប់ដើមជាភាសាជប៉ុន ដែលត្រូវបាន បង្កើតឡើងដោយ មជ្ឈមណ្ឌលជួយគាំទ្រទីលំនៅរបស់ជនបរទេស នៅ ខេត្តកាណាហ្កាវ៉ា។

ដេប៉ាតឺម៉ង់ ជនបរទេសនៃខេត្តកាណាហ្កាវ៉ា

ផ្លូវនីពប៉ុនអូដូរី១ ក្រុងយ៉ូកូហាម៉ា

លេខទូរស័ព្ទ: 045-210-1111 (បណ្តាញផ្ទាល់3748)

លេខទូរសារ: 045-212-2753